**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០៧. សរ**

# សារាចរ
## ស្តីពី
## ការប្រើប្រាស់សម្លៀកបំពាក់របស់សិស្សានុសិស្សខ្មែរឥស្លាម នៅគ្រឹះស្ថានសិក្សានានា

កន្លងមក នៅតាមគ្រឹះស្ថានសិក្សានានា សិស្សានុសិស្សមានឯកសណ្ឋានទៅតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សានីមួយៗ ។

រដ្ឋធម្មនុញ្ញត្រង់មាត្រា៣១ ចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើប្រាស់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃឡើយ ។ ការប្រើប្រាស់សិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តិតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

តាមខ្លឹមសារមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាខាងលើ និងដើម្បីបង្កលក្ខណៈសម្បត្តិឱ្យសិស្ស និស្សិតជាខ្មែរឥស្លាម ពិសេសសិស្សនិស្សិតជានារីភេទនៃបងប្អូនខ្មែរឥស្លាម រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដល់គ្រឹះស្ថានសិក្សារដ្ឋ និងគ្រឹះស្ថានសិក្សាឯកជនទាំងអស់ ឱ្យផ្តល់សិទ្ធិ និងសេរីភាពដល់សិស្សានុសិស្សខ្មែរឥស្លាម គ្រប់រូបដែលកំពុងសិក្សានៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន ក្នុងការជ្រើសរើសសម្លៀកបំពាក់មកសិក្សា ឬ ចូលរួមក្នុងពិធីផ្សេងៗ ទៅតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សាក៏បាន ឬ តាមប្រពៃណីខ្មែរឥស្លាមក៏បាន ។

ទទួលបានសារាចរនេះ ក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រឹះស្ថានសិក្សារដ្ឋ គ្រឹះស្ថានសិក្សាឯកជន និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *ឯកសារ- កាលប្បវត្តិ*
- *រាជកិច្ច*